ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ១៧០៤ កសក

# លិខិតរួម

**គោរពជូន៖ -ឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**-ឯកឧត្តម លោក លោកស្រី ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួង**

| ល.រ | កាលបរិច្ឆេទលិខិត | ចំនួន | សេចក្តីផ្សេងៗ |
|---|---|---|---|
| ១ | -របាយការណ៍ស្តីពីសភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ **ប្រចាំខែកុម្ភៈ ឆ្នាំ២០២២** និងទិសដៅអនុវត្តបន្ត ............... | ១ច្បាប់ | "ដើម្បីជូនជ្រាប" ---------- |

ថ្ងៃអង្គារ ៩កើត ខែពិសាខ ឆ្នាំខាល ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ២០២២

**ត.ប.រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**អគ្គលេខាធិការ**

**ស្រី វុឌ្ឍី**

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨/៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣ ២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍
# ស្ដីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំខែកុម្ភៈ ឆ្នាំ២០២២ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងខែកុម្ភៈនេះ ការងារបង្កបង្កើនផលស្រូវរដូវប្រាំងសម្រេចបាន ៦៣៧ ១៦៥ហ.ត ស្មើនឹង១៣៧,៨៣% នៃផែនការចំនួន ៤៦២ ២៨០ហ.ត។ វិធានការជួយសង្គ្រោះបន្ទាន់ និងវិធានការជំរុញផលិតកម្មដំណាំ ការចិញ្ចឹមសត្វ និងវារីវប្បកម្មត្រូវបានដាក់ចេញ និងអនុវត្តយ៉ាងសកម្មដើម្បីជួយដល់កសិករ។ រីឯការចូលរួមទប់ស្កាត់បទល្មើស ជាពិសេសបទល្មើសព្រៃឈើ បទល្មើសជលផល បទល្មើសចលនាសត្វដោយខុសច្បាប់ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួង។ ចំណែកឯការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្ម ការជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពបានប្រព្រឹត្តទៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍សំខាន់ៗក្នុងខែកុម្ភៈ ឆ្នាំ២០២២នេះ គឺបានរៀបចំកិច្ចប្រជុំការងារចាំបាច់ ការប្រជុំពិចម្ងាយ រួមទាំងការបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាផងដែរ។ ចំពោះលទ្ធផល និងសកម្មភាពការងារតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំ២០២២រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចបានក្នុងខែកុម្ភៈ ឆ្នាំ២០២២នេះ មានដូចតទៅ៖

## II- លទ្ធផលសម្រេចបានតាមបណ្ដាផ្នែក

### ១ លទ្ធផលផ្នែកដាំដុះ

#### ១.១ ផលិតកម្មដំណាំស្រូវរដូវប្រាំង

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ៦៣៨ ៤២១ហ.ត ក្នុងនោះ ភ្ជួររាស់ដោយគោ-ក្របីមានចំនួន ១ ៦០៥ហ.ត ស្មើនឹង០,២៥% និងដោយគ្រឿងយន្តចំនួន ៦៣៦ ៨១៦ហ.ត ស្មើនឹង៩៩,៧៥%
- ផ្ទៃដីសាបសម្រេចបានចំនួន ៥ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ៦៣៧ ១៦៥ហ.ត ស្មើនឹង១៣៧,៨៣% នៃផែនការចំនួន ៤៦២ ២៨០ហ.ត លើសឆ្នាំមុន ៦ ២៨២ហ.ត។

#### ១.២ ល្បឿនការងារប្រមូលផលស្រូវប្រាំង

-ការប្រមូលផលស្រូវប្រាំងសម្រេចបានចំនួន ២៥៦ ៧៣១ហ.ត ដោយទទួលបរិមាណផលសរុបចំនួន ១ ១៤៨ ០៧៥តោន និងទទួលទិន្នផលគិតជាមធ្យម ៤,៤៧២តោន/ហ.ត។

#### ១.៣ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្មរដូវប្រាំង

-ដំណាំសាកវប្បកម្មអនុវត្តបានសរុបចំនួន ៣៣ ១៨៧ហ.ត ស្មើនឹង៩២,៨០% នៃផែនការចំនួន ៣៥ ៧៦០ហ.ត តិចជាងឆ្នាំមុន ៣ ១២៨ហ.ត

-ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៩៣ ៥៨១ហ.ត ស្មើនឹង១០៤,២០% នៃផែនការចំនួន ៨៩ ៨១០ហ.ត លើសឆ្នាំមុន ១២ ៧១៤ហ.ត។

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣ ២១៧ ៣២០
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia Phone: (023) 726 128 / 726 129, Fax: (855) 23 217 320

## ១.៤ ការនាំចេញផលិតផលកសិកម្ម

### ១.៤.១ ការនាំចេញអង្ករ

ការនាំចេញអង្ករក្នុងរយៈពេល២ខែឆ្នាំ២០២២ មានចំនួន ១០៣ ០៥៨តោន កើនឡើងចំនួន ២៦ ៨៣៦តោន (៣៥,២១%) បើធៀបនឹងបរិមាណនាំចេញក្នុងរយៈពេល២ខែឆ្នាំ២០២១ មានចំនួន ៧៦ ២២២តោន។ ការនាំចេញអង្ករក្នុងខែកុម្ភៈ ឆ្នាំ២០២២ មានចំនួន ៥០ ០២២តោន កើនឡើងចំនួន៨ ០៧៣តោន (១៩,២៤%) បើធៀបនឹងខែកុម្ភៈ ឆ្នាំ២០២១ មានចំនួន ៤១ ៩៤៩តោន

អង្ករក្រអូបគ្រប់ប្រភេទមានចំនួន ៨១ ២៨៩តោន ស្មើនឹង៧៨,៨៧% អង្ករសគ្រប់ប្រភេទមានចំនួន ២១ ៧០០តោន ស្មើនឹង ២១,០៦% និងអង្ករចំហុយមានចំនួន ៦៩តោន ស្មើនឹង០,០៧%

បរិមាណអង្ករបាននាំចេញទៅកាន់ទិសដៅសហភាពអឺរ៉ុបចំនួន ២០ប្រទេស មានបរិមាណសរុបចំនួន ២៦ ៥០៧តោន (កើនឡើងចំនួន ៧ ៥១១តោន ស្មើនឹង៣៩,៥៤%) ទិសដៅប្រទេសចិនមានបរិមាណសរុបចំនួន ៥៦ ៣៨៥តោន (កើនឡើងចំនួន ១៨ ៧៥៥តោន ស្មើនឹង៤៩,៨៤%) ទិសដៅអាស៊ានចំនួន ៣ប្រទេស មានបរិមាណសរុបចំនួន ៩ ៣៧០តោន (កើនឡើងចំនួន ៣ ១៤១តោន ស្មើនឹង៥០,៤៣%) និងទិសដៅដទៃទៀតចំនួន ១៦ប្រទេសមានបរិមាណសរុប ១០ ៧៩៦តោន (ថយចុះចំនួន ២ ៥៧១តោន ស្មើនឹង-១៩,២៣%)

ក្រុមហ៊ុនបាននាំចេញអង្ករមានចំនួន ៤១ក្រុមហ៊ុន ហើយបរិមាណអង្ករបាននាំចេញដោយក្រុមហ៊ុនធំៗចំនួន ១០ មានរហូតដល់ ៧៧ ០៣៩តោន ស្មើនឹង៧៥,០២% និងក្រុមហ៊ុន៣១ដទៃទៀតបាននាំចេញត្រឹមតែ ២៦ ០១៩តោន ស្មើនឹង២៤,៩៨%។

### ១.៤.២ ការនាំចេញស្រូវ

ការនាំចេញស្រូវរយៈពេល២ខែឆ្នាំ២០២២ មានចំនួន ៦៥១ ១០១តោន ទៅកាន់ប្រទេសវៀតណាម (មានវិញ្ញាបនបត្រភូតគាមអនាម័យចំនួន ៤១៣ ៧៧៥តោន) ដែលមានការកើនឡើងចំនួន ៩២ ០៦៨តោន (១៦,៤៧%) បើធៀបនឹងរយៈពេល២ខែឆ្នាំ២០២១ មានចំនួន ៥៥៩ ០៣៣តោន។

### ១.៤.៣ ការនាំចេញកសិផលក្រៅពីស្រូវ-អង្ករ

បរិមាណការនាំចេញកសិផលក្រៅពីស្រូវ-អង្កររយៈពេល២ខែឆ្នាំ២០២២ មានចំនួន ១ ៣១៨ ៦៤២,៧០តោន កើនឡើងចំនួន ៦ ៥៧០,៣៣តោន ស្មើនឹង០,៥០% បើធៀបនឹងរយៈពេល២ខែឆ្នាំ២០២១ មានចំនួន ១ ៣១២ ០៧២,៣៧តោន ដែលក្នុងនោះរួមមាន៖

- ចំណិតដំឡូងមីក្រៀមមានចំនួន ៨៣១ ៨៥០តោន (កើនឡើងចំនួន ៣,៦៦%) ក្នុងនោះនាំចេញទៅប្រទេសថៃចំនួន ៦០០ ៨០០តោន និងប្រទេសវៀតណាមចំនួន ២៣១ ០៥០តោន
- ដំឡូងមីស្រស់មានចំនួន ១៧៥ ៨០០តោន (កើនឡើងចំនួន ១៣,៦០%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ១៣៧ ១០០តោន និងប្រទេសថៃចំនួន ៣៨ ៧០០តោន
- ម្សៅដំឡូងមីមានចំនួន ១៣ ៦៩៨តោន (កើនឡើងចំនួន ១៣២,៤៤%) ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ១៣ ៥៤៣តោន សហរដ្ឋអាមេរិកចំនួន ១៣៦តោន និងប្រទេសអ៊ីតាលីចំនួន ១៩តោន
- កាកសំណល់ដំឡូងមីមានចំនួន ២ ៣៩១,៣៩តោន (កើនឡើងចំនួន ៧៤,៦៨%) នាំចេញទៅប្រទេសចិន
- គ្រាប់ស្វាយចន្ទីឆៅមានចំនួន ៥៤ ៩៩៣,៥៨តោន (ថយចុះចំនួន -៣០,៧៩%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៥៤ ៩៨០តោន និងប្រទេសចិនចំនួន ១៣,៥៨តោន
- គ្រាប់ស្វាយចន្ទីកែច្នៃមានចំនួន ៧១,៦៣តោន (កើនឡើងចំនួន ១០០%) ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ៣០តោន ប្រទេសថៃចំនួន ៣០តោន ប្រទេសជប៉ុន ៩,៧០តោន និងកោះតៃវ៉ាន់ ១,៩៣តោន
- គ្រាប់ពោតមានចំនួន ៣៤ ៦៤៦,៨៤តោន (ថយចុះចំនួន -៥៦,០៦%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៣៤ ១៦០តោន កោះតៃវ៉ាន់ចំនួន ៤៧៤,៥៤តោន និងប្រទេសកូរ៉េចំនួន ១២,៣០តោន
- គ្រាប់សណ្តែកបាយមានចំនួន ៣ ៨០០តោន (កើនឡើងចំនួន ១០០%) នាំចេញទៅប្រទេសវៀតណាម
- គ្រាប់សណ្តែកសៀងមានចំនួន ៣១ ៨៦០តោន (កើនឡើងចំនួន ១០០%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៣០ ៩៦០តោន និងប្រទេសថៃចំនួន ៩០០តោន
- ផ្លែចេកស្រស់មានចំនួន ៦០ ៩៨៧,២៧តោន (ថយចុះចំនួន -១៩,៣៨%) ក្នុងនោះនាំចេញទៅប្រទេសចិនចំនួន ៦០ ៣៤៥,៧១តោន និងប្រទេសវៀតណាមចំនួន ៦៤១,៥៦តោន

- ផ្លែក្រូចថ្លុងមានចំនួន ៣ ៧៥០តោន (ថយចុះចំនួន -០,៨៨%) នាំចេញទៅប្រទេសថៃ

- ផ្លែស្វាយស្រស់មានចំនួន ៤៣ ២១៥,០៣តោន (ថយចុះចំនួន -១,០៧%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាម ចំនួន ១៩ ៩២៣,៤៩តោន ប្រទេសចិនចំនួន ១២ ០១៨,៦៧តោន ប្រទេសថៃចំនួន ១១ ១៨១,១២តោន និងប្រទេសកូរ៉េចំនួន ៩១,៧៥តោន

- ដំណាប់ស្វាយមានចំនួន ២ ៦៥៨,៣៦តោន (កើនឡើងចំនួន ៦៩,៤០%) ក្នុងនោះនាំចេញទៅប្រទេសចិន ចំនួន ២ ១២៨,៤២តោន ប្រទេសវៀតណាមចំនួន ២០០តោន ប្រទេសហ្វីលីពីនចំនួន ១៩២,៥៥តោន ប្រទេសថៃចំនួន ១០២,៨២តោន ប្រទេសជប៉ុនចំនួន ២២តោន ចក្រភពអង់គ្លេសចំនួន ៩,៧៨តោន ប្រទេសអ៊ីតាលីចំនួន ២,៥២តោន និងប្រទេសកូរ៉េចំនួន ០,២៧តោន

- ទឹកស៊ីរ៉ូស្វាយមានចំនួន ៥០តោន (ថយចុះចំនួន -៩០,៩៤%) នាំចេញទៅប្រទេសចិន

- ដូងប្រេងមានចំនួន ៤ ៧២០តោន (ថយចុះចំនួន -៣៤,២៣%) ក្នុងនោះនាំចេញទៅប្រទេសឥណ្ឌាចំនួន ៣ ៩២០តោន និងប្រទេសម៉ាឡេស៊ីចំនួន ៨០០តោន

- ម្រេចមានចំនួន ៩៤៤,២៨តោន (កើនឡើងចំនួន ៣៨៥,៦៤%) ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៩១០,០១តោន ប្រទេសម៉ាឡេស៊ីចំនួន ១៣,៦៤តោន ប្រទេសប៊ែលហ្ស៊ិកចំនួន ៥,៧៣តោន ប្រទេសអាល្លឺម៉ង់ចំនួន ៤,៦០តោន ប្រទេសបារាំងចំនួន ៤,៥០តោន សាធារណរដ្ឋឆេកចំនួន ២,៣០តោន ប្រទេសកាណាដាចំនួន ១តោន សហរដ្ឋអាមេរិកចំនួន ០,៩២តោន ចក្រភពអង់គ្លេសចំនួន ០,៩០តោន ប្រទេសស៊ុយអ៊ែតចំនួន ០,២៩តោន ប្រទេសកាហ្សាក់ស្ថានចំនួន ០,២៩តោន និងប្រទេសអូស្ត្រាលីចំនួន ០,១០តោន

- ថ្នាំជក់មានចំនួន ៤០០,៨១តោន ក្នុងនោះនាំចេញទៅប្រទេសវៀតណាមចំនួន ៣៨៥,៧០តោន និងប្រទេសហ្វីលីពីនចំនួន ១៥,១១តោន

- បន្លែចម្រុះមានចំនួន ១៦,៤៤តោន (កើនឡើងចំនួន ១៦,១៨%) នាំចេញទៅប្រទេសបារាំង

- ម្ទេសស្រស់មានចំនួន ៧ ៧១០តោន (ថយចុះចំនួន -៧៦,២២%) នាំចេញទៅប្រទេសថៃ

- ម្ទេសក្រៀមមានចំនួន ០,១៦តោន (កើនឡើងចំនួន ១០០%) នាំចេញទៅប្រទេសប៊ែលហ្ស៊ិក

- ផលិតផលចំនួន ៣៥មុខ ផ្សេងទៀតមានចំនួន ៤៥ ០៧៨,៩១តោន។

## ២ ផ្នែកផលិតកម្មកៅស៊ូ

### ២.១ ផ្ទៃដីកៅស៊ូ

- ផ្ទៃដីកៅស៊ូសរុបចំនួន ៤០៤ ០៤៤ហ.ត ក្នុងនោះ ផ្ទៃដីចម្ការកៅស៊ូកសិ-ឧស្សាហកម្មចំនួន ៤៧ ៩៤៤ហ.ត ផ្ទៃដីចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ចចំនួន ១៩២ ៤០២ហ.ត និងផ្ទៃដីចម្ការកៅស៊ូគ្រួសារចំនួន ១៦៣ ៦៩៨ហ.ត។ ផ្ទៃដីចៀរជ័រចំនួន ៣១០ ១៩៣ហ.ត ស្មើនឹង៧៧% និងផ្ទៃដីថែទាំចំនួន ៩៣ ៨៥១ហ.ត ស្មើនឹង២៣%។

### ២.២ ផលិតកម្មកៅស៊ូ

- ផលិតផលជ័រកៅស៊ូសម្រេចបានចំនួន ៣៤ ១៣៧តោន កើនឡើងចំនួន១ ២៩៤តោន ស្មើនឹង៤% ធៀបនឹងខែកុម្ភៈ ឆ្នាំ២០២១

- ផលិតផលឈើកៅស៊ូសម្រេចបានចំនួន ៤៨៦ម៣។

### ២.៣ ការនាំចេញកៅស៊ូ

- បរិមាណបញ្ចេញលក់សម្រេចបានចំនួន ៣២ ៥២០តោន កើនឡើងចំនួន ១ ៦៦៧តោន ស្មើនឹង៥% ធៀបនឹងខែកុម្ភៈ ឆ្នាំ២០២១

- បរិមាណបញ្ចេញលក់ឈើកៅស៊ូសម្រេចបានចំនួន ៤៨៦ម៣។

### ២.៤ តម្លៃកៅស៊ូ

- តម្លៃលក់ជ័រកៅស៊ូមធ្យមក្នុងខែកុម្ភៈ គឺ១ ៥៨៦ដុល្លារ/តោន បានកើនឡើងចំនួន២១ដុល្លារ/តោនស្មើនឹង១% ធៀបនឹងខែកុម្ភៈ ឆ្នាំ២០២១

- តម្លៃលក់ឈើកៅស៊ូមធ្យមក្នុងខែកុម្ភៈ គឺ២៧៨.៩៨ដុល្លារ/ម៣

- តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារក្នុងខែកុម្ភៈ គឺទឹកជ័រ (DRC 100%) មានការប្រែប្រួលពី ៥ ៩០០៛/គ.ក្រ ដល់ ៦ ០០០៛/គ.ក្រ និងជ័រកក (DRC50%) មានការប្រែប្រួលពី ២ ៦០០៛/គ.ក្រ ដល់ ៣ ១៥០៛/គ.ក្រ។

## ៣ ផ្នែកព្រៃឈើ

### ៣.១ ការងារព្រៃឈើ

- ផ្ដល់ជូនផែនទី PDF សម្រាប់ប្រើប្រាស់ក្នុងកម្មវិធី Avenza ដល់ផ្នែករដ្ឋបាលព្រៃឈើចំនួន ១៤ មានផ្នែករដ្ឋបាលព្រៃឈើស្ទឹងត្រែង សៀមប៉ាង ចំការមន សំរោង បន្ទាយអំពិល មោងឫស្សី រតនៈមណ្ឌល ស្ទោង ប៉ៃលិន ស្រែអំបិល ដងទង់ ត្រើយស្លា ត្រើយឆ្វេង និងផ្នែករដ្ឋបាលព្រៃឈើសាលាក្រៅ

- ផ្ដល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្តសរុបចំនួន ២៨គ្រឿង និងយានយន្តចំនួន ៤១គ្រឿង ជូនក្រុមហ៊ុនចំនួន ២ក្រុមហ៊ុន

- ផ្ដល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើជូនក្រុមហ៊ុនចំនួន ៣ក្រុមហ៊ុន ដែលមានឈើហ៊ុបមូលចំនួន ៣ ៣៣៤ម៣ កូនឈើចំនួន ២៥ ៦៥០ដើម អុសចម្រុះចំនួន ១០ ៤២៣ស្ទែរ និងឫស្សីចំនួន ៣០០តោន

- ធ្វើសារពើភ័ណ្ឌវាយតម្លៃប៉ាន់ស្មានធនធានព្រៃឈើចំនួន ២ក្រុមហ៊ុន។

### ៣.២ ការងារអភិរក្សសត្វព្រៃ

- ចុះធ្វើការប្រមូលម៉ាស៊ីនថតរូបស្វ័យប្រវត្តចំនួន ១៤គ្រឿង ដែលបានដំឡើងកាលពីខែធ្នូ ឆ្នាំ២០២១ ក្នុងតំបន់គម្រោងរេដបូកទំរីង ខេត្តកំពង់ធំ ដើម្បីធ្វើការពិនិត្យផ្ទៀងផ្ទាត់ពីចំនួន និងប្រភេទសត្វព្រៃ ដោយធ្វើការវិភាគលើរូបភាព

- ចេញលិខិតអនុញ្ញាតថែរក្សាសត្វព្រៃជាលក្ខណៈគ្រួសារចំនួន ១ច្បាប់ ដែលមានទីតាំងស្ថិតនៅខេត្តកំពង់ស្ពឺ

- ចេញលិខិតអនុញ្ញាតដឹកជញ្ជូនសត្វព្រៃជូនក្រុមហ៊ុនចំនួន ៧ច្បាប់មានសត្វស្វាក្ដាមសរុបចំនួន ២ ៩៩១ក្បាល សម្រាប់ដឹកជញ្ជូនទៅកាន់មាត់ច្រកអន្តរជាតិនៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ១ ៨៨០ក្បាល និងដឹកជញ្ជូនក្នុងស្រុកចំនួន ១ ១១១ក្បាល។

### ៣.៣ កសិដ្ឋានចិញ្ចឹម បង្កាត់ពូជស្វាក្ដាម និងការសង្គ្រោះសត្វព្រៃ

- ក្រុមហ៊ុនចំនួន៧ដែលមានកសិដ្ឋានស្រាវជ្រាវ ចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្ដាមយកកូននាំចេញចំនួន ៨ទីតាំង ស្ថិតនៅរាជធានីភ្នំពេញ ខេត្តកំពង់ធំ សៀមរាប កំពង់ចាម កំពង់ស្ពឺ ពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំងមានស្វាក្ដាមចំនួន ១១២ ២៩១ក្បាល ក្នុងនោះកូនកើតក្នុងខែចំនួន ៨ ៨៥៦ក្បាល

- នៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅមានសត្វព្រៃសរុបចំនួន ១ ៦៧៨ក្បាល (បក្សីចំនួន ៥៨ប្រភេទ ថនិកសត្វចំនួន ៤៤ប្រភេទ និងល្មូនចំនួន ១៦ប្រភេទ) និងបានសង្គ្រោះសត្វព្រៃថ្មីចំនួន ៦៨ក្បាល និងព្យាបាលចំនួន ២៦ក្បាល ស្តារលទ្ធភាពជីវសាស្ត្រសត្វព្រៃចំនួន ៩៥ក្បាល ប៉ុន្តែពុំទាន់បានដោះលែងទៅព្រៃធម្មជាតិវិញទេ

- ក្រុមល្បាតសហគមន៍ចំនួន ២៦នាក់ ដើរល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន ៥គឺៈ អារ៉ែង ឆាយរាប តំបន់ស្ពានក្រពើស្ទឹងដាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់) រកឃើញក្រពើចំនួន ២ក្បាល និងសត្វព្រៃ ២៥ប្រភេទ

- តាមដានក្រពើប្រចាំឆ្នាំដោយរកឃើញលាមកក្រពើចំនួន ៦៦ដុំ ឃើញក្រពើផ្ទាល់ចំនួន ២ក្បាល និងស្លាកស្នាមដានជើងក្រពើចំនួន ៤កន្លែង

- ជួសជុលផ្លូវដោយក្រាលក្រួសក្រហមប្រវែង ៨ម៉ែត្រ និងជួសជុលដំបូលក្បុសទំហំ ១៧៥ម៉ែត្រការ៉េនៅក្នុងតំបន់សួនសត្វ។

### ៣.៤ ការងារដាំដើមឈើ

- បាននិងកំពុងថែទាំប្រឡាយការពារចម្ការគ្រញូងសរុបប្រវែង ៥១ ៥៧៨ម៉ែត្រ ស្ថិតក្នុងខេត្តកំពង់ធំ ព្រះសីហនុ ស្វាយរៀង និងខេត្តសៀមរាប

- បាននិងកំពុងថែទាំចម្ការឈើសរុបទំហំ ៧៤៧ហ.ត ក្នុងនោះចម្ការពូជឈើទំហំ ៩៤ហ.ត ឡូតិ៍បង្ហាញកសិ-រុក្ខកម្មទំហំ ៣៩ហ.ត ចម្ការឈើដាំទំហំ ៥៨៤ហ.ត និងចម្ការរុក្ខទិវា៩ កក្កដាទំហំ ៣០ហ.ត ស្ថិតក្នុងខេត្តកំពត កណ្ដាល សៀមរាប ព្រះសីហនុ ស្វាយរៀង កំពង់ធំ និងខេត្តក្រចេះ

- បណ្ដុះកូនឈើបានចំនួន ៣៧ ៧៤០ដើម ក្នុងនោះថ្នាលបណ្ដុះកូនឈើតាមបណ្ដាខណ្ឌរដ្ឋបាលព្រៃឈើរាជធានី-ខេត្តចំនួន ១៨ ០០០ដើម និងថ្នាលបណ្ដុះកូនឈើចំនួន៦ទៀតចំនួន ១៩ ៧៤០ដើម។

### ៣.៥ ការងារនីតិកម្ម និងវិវាទ

- សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃទទួលពីរដ្ឋបាលព្រៃឈើមូលដ្ឋាន និងក្រុមអន្តរាគមន៍បង្ក្រាបបទល្មើសសត្វព្រៃចល័តនៃរដ្ឋបាលព្រៃឈើសរុបចំនួន ៥៩ករណី ក្នុងនោះសំណុំរឿងបទល្មើសព្រៃឈើត្រូវពិន័យអន្តរការណ៍ចំនួន ១៧ករណី និងសំណុំរឿងបទល្មើសព្រៃឈើដែលត្រូវបញ្ជូនទៅតុលាការចំនួន ៤២ករណី

- វត្ថុតាងនៃបទល្មើសព្រៃឈើបានចាប់ឃាត់ និងដកហូតរួមមានឈើមូល-ជ្រុងសរុបចំនួន ០,២៦៣ម៣ ឈើអារសរុបចំនួន ១៤០ម៣ សត្វព្រៃចម្រុះប្រភេទចំនួន ២៣៩ក្បាល និង៣៤៣គ.ក្រ ផ្ទៃដីព្រៃឈើកាប់រានទំហំ ១១៨ហ.ត

- វត្ថុតាងសត្វព្រៃ និងសំណាកសត្វព្រៃប្រមូលតាមរយៈការប្រគល់-ទទួលចំនួន ៧២ករណី ធ្វើកិច្ចសន្យាចំនួន ១៧ករណី ធ្វើការដកហូតចំនួន ១៩ករណី

- ធ្វើបច្ចុប្បន្នភាពសំណុំរឿងបទល្មើសព្រៃឈើ និងសត្វព្រៃតាមរយៈការបង់ប្រាក់ពិន័យដោយតុលាការចំនួន ៤ករណី។

### ៣.៦ ការងារឧស្សាហកម្ម និងពាណិជ្ជកម្ម

- ចុះពិនិត្យសំណើសុំពន្យារសុពលភាពរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើប្រភេទធំ (ប្រកចេញចូលតែមួយ) ចំនួន ៣កន្លែងស្ថិតនៅក្នុងរាជធានីភ្នំពេញ កណ្តាល និងខេត្តបាត់ដំបង

- ក្រុមហ៊ុនចំនួន២នាំចេញផលិតផលរានទេវតា និងឈើកែច្នៃទៅក្រៅប្រទេសមានបរិមាណចំនួន ២១៣ម៣

- ក្រុមហ៊ុនចំនួន១នាំចូលឈើកែច្នៃមានបរិមាណចំនួន ៧០ម៣

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុនចំនួន២មានធ្យូងអាកាស្យាចំនួន ៨៨តោន និងជ័រទឹកចំនួន ២០តោន។

### ៣.៧ ការងារចំណូលព្រៃឈើ

- ចំណូលពីថ្លៃសួយសារផលអនុផលព្រៃឈើចំនួន ៤៩៣ ៤៨៨ ៤០១រៀល និង១៤៩ ២៧២,៨៤ដុល្លារ។

## ៤ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

**៤.១ ការងារផលិតកម្មសត្វ៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តារាជធានី-ខេត្តរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្តៈ (ក) ការងារកែលម្អពូជតាមរយៈការចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព (ខ) ការលើកកម្ពស់ការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងបន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើសួនដំណាំចំណីសត្វ ការផ្តល់ពូជស្មៅដល់កសិករ និងភ្នាក់ងារសុខភាពសត្វភូមិ និងចុះពិនិត្យនិងកែសម្រួលឡជីវឧស្ម័នដែលបានសាងសង់រួចហើយ ដែលមានបញ្ហាបច្ចេកទេសនៅតាមខេត្តគោលដៅ។

### ៤.២ ការងារសុខភាពសត្វ

- **លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖** ចុះត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបបទល្មើសចលនាសត្វ និងផលិតផលសត្វសរុបចំនួន ៤ករណី មិនមានលិខិតអនុញ្ញាតត្រឹមត្រូវទាំងអស់។ រាជធានី-ខេត្តចំនួន ២៤បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ១៨ ៦៦២លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។
- **ការងារផ្សព្វផ្សាយបច្ចេកទេស**

- ចុះប្រជុំផ្សព្វផ្សាយស្តីពីបច្ចេកទេសចិញ្ចឹមសត្វ និងជំងឺឆ្លងសត្វនៅតាមបណ្តាខេត្តចំនួន២។

- **ការងារនីតិកម្ម និងវិវាទ**

- កំពុងប្រជុំពិភាក្សាផ្ទៃក្នុងនាយកដ្ឋានលើសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីគំរូសំណុំលិខិតដោះស្រាយបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ

- កំពុងប្រជុំពិភាក្សាផ្ទៃក្នុងនាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេសនិងនីតិកម្មលើសេចក្តីព្រាងប្រកាសស្តីពីនីតិវិធីនៃការចេញលិខិតអនុញ្ញាត និងបទដ្ឋានបច្ចេកទេសបសុព្យាបាលសម្រាប់ទីកន្លែងព្យាបាលសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ និងទីកន្លែងអាជីវកម្មសត្វ

- កំពុងប្រជុំពិភាក្សាផ្ទៃក្នុងនាយកដ្ឋានផ្សព្វផ្សាយបច្ចេកទេស និងនីតិកម្ម និងចូលរួមរៀបចំលិខិតបទដ្ឋានគតិយុត្តទំនាក់ទំនងការងារវិមជ្ឈការ និងវិសហមជ្ឈការ។ ។

### ៤.៣ ការងារស្រាវជ្រាវ

- **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោភ្នំតាម៉ៅមានគោសរុបចំនួន ១១៥ក្បាល។

• **ការងារស្រាវជ្រាវសុខភាពសត្វ៖** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺ និងងាប់ ឬនៅតាមសត្តឃាតដ្ឋានសរុបបានចំនួន ២ ៨៧៦វត្ថុវិភាគ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្តាសាយបក្សី និងជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF)។

## ៥ ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

#### ៥.១.១ នេសាទទឹកសាប

- ដាយត្រីបានបញ្ចប់ត្រឹមចំនួន ៦៥០តោន ស្មើនឹង៦,៥០% នៃផែនការចំនួន ១០ ០០០តោន ប្រៀបធៀបខែកុម្ភៈ ឆ្នាំ២០២១ ថយចុះចំនួន ៦៦០តោន

- នេសាទគ្រួសារក្នុងដែននេសាទអនុវត្តបានចំនួន ១២ ៣០០តោន សរុបរយៈពេល២ខែចំនួន ២១ ៥០០តោន ស្មើនឹង៧,១៧% នៃផែនការចំនួន ៣០០ ០០០តោន ប្រៀបធៀបខែកុម្ភៈ ឆ្នាំ២០២១ ថយចុះចំនួន ៣ ១០០តោន

- នេសាទគ្រួសារតាមវាលស្រែអនុវត្តបានចំនួន ៣ ០០០តោន សរុបរយៈពេល២ខែចំនួន ៥ ៨០០តោន ស្មើនឹង៤,១៤% នៃផែនការចំនួន ១៤០ ០០០តោន ប្រៀបធៀបខែកុម្ភៈ ឆ្នាំ២០២១ ថយចុះចំនួន ២ ៧០០តោន។

#### ៥.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន ៨ ៥០០តោន សរុបរយៈពេល២ខែចំនួន ១៦ ៤០០តោន ស្មើនឹង១២,៦២% នៃផែនការចំនួន ១៣០ ០០០តោន ប្រៀបធៀបខែកុម្ភៈ ឆ្នាំ២០២១ កើនឡើងចំនួន ៣០០តោន។

### ៥.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គាអនុវត្តបានចំនួន ៣ ៥៧៤តោន សរុបរយៈពេល២ខែចំនួន ៥ ៩១០តោន ស្មើនឹង១,៦៤% នៃផែនការចំនួន ៣៦០ ០០០តោន ប្រៀបធៀបខែកុម្ភៈ ឆ្នាំ២០២១ ថយចុះចំនួន ១៨ ៤៩០តោន

- ការចិញ្ចឹមក្រពើអនុវត្តបានចំនួន ១១ ៥០០ក្បាល សរុបរយៈពេល២ខែចំនួន ២០ ៤០០ក្បាល ស្មើនឹង៦,៨០% នៃផែនការចំនួន ៣០០ ០០០ក្បាល ប្រៀបធៀបខែកុម្ភៈ ឆ្នាំ២០២១ ថយចុះចំនួន ២ ៦០០ក្បាល

- ការភ្ញាស់កូនត្រីពូជអនុវត្តបានចំនួន ២១ ៥០០ ០០០កូន សរុបរយៈពេល២ខែចំនួន ៣៥ ១៥០ ០០០កូន ស្មើនឹង១១,៧២% នៃផែនការចំនួន ៣០០ ០០០ ០០០កូន ប្រៀបធៀបខែកុម្ភៈ ឆ្នាំ២០២១ ថយចុះចំនួនប្រមាណ ២ ៩៥០ ០០០កូន។

### ៥.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបក្នុងរដូវនេសាទអនុវត្តចំនួន ៥ ៣០០តោន សរុបរយៈពេល២ខែចំនួន ៨ ៨០០តោន ស្មើនឹង១១% នៃផែនការចំនួន ៨០ ០០០តោន ប្រៀបធៀបខែកុម្ភៈ ឆ្នាំ២០២១ ថយចុះចំនួន ២ ១១០តោន

- ផលនេសាទសមុទ្រអនុវត្តបានចំនួន ១ ៤០០តោន សរុបរយៈពេល២ខែចំនួន ២ ៣៥០តោន ស្មើនឹង១៩,៥៨% នៃផែនការចំនួន ១២ ០០០តោន ប្រៀបធៀបខែកុម្ភៈ ឆ្នាំ២០២១ កើនឡើងចំនួន ៥០តោន

- ការផលិតទឹកត្រីអនុវត្តបានចំនួន ៨ ០០០ ០០០លីត្រ សរុបរយៈពេល២ខែចំនួន ១០ ៥០០ ០០០លីត្រ ស្មើនឹង២១% នៃផែនការចំនួន ៥០ ០០០ ០០០លីត្រ ប្រៀបធៀបខែកុម្ភៈ ឆ្នាំ២០២១ ថយចុះចំនួន ១ ០០០ ០០០លីត្រ។

### ៥.៤ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើសជលផល

- សំណុំរឿងបទល្មើសជលផលមានចំនួន ១៥៤ករណី ប្រៀបធៀបខែកុម្ភៈ ឆ្នាំ២០២១ ថយចុះចំនួន ៣៩ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ១៤៨ករណី និងសមុទ្រចំនួន ៦ករណី។

### ៥.៥ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់នាំចេញចំនួន ២៩២តោន សរុបរយៈពេល២ខែចំនួន ៤០៦តោន ស្មើនឹង៥,០៨% នៃផែនការចំនួន ៨ ០០០តោន ប្រៀបធៀបខែកុម្ភៈ ឆ្នាំ២០២១ ថយចុះចំនួន ២៦៤តោន

- ផលនេសាទកែច្នៃនាំចេញចំនួន ១៦តោន សរុបរយៈពេល២ខែចំនួន ៤១តោន ស្មើនឹង២,០៥% នៃផែនការចំនួន ២ ០០០តោន ប្រៀបធៀប ខែកុម្ភៈ ឆ្នាំ២០២១ ថយចុះចំនួន ១២៩តោន។

### ៥.៦ ការប្រមូលថវិកា

- ចំណូលពីសេវាផ្សេងៗក្នុងផ្នែកជលផលបានចំនួន ១១៩ ៨៧៧ ៨៧៥រៀល សរុបរយៈពេល២ខែចំនួន ១២៤ ៧៦៧ ៨៧៥រៀល ស្មើនឹង៣៤,៧៣% នៃផែនការចំនួន ៣៥៩ ២០០ ០០០រៀល ប្រៀបធៀបខែកុម្ភៈ ឆ្នាំ២០២១ កើនឡើងចំនួន ៩៣ ២៣៤ ២៥០រៀល។

## ៦ ផ្នែកអន្តរាធិការដ្ឋាន

- ពុំមានការទទួលពាក្យបណ្តឹង

- ស្រាវជ្រាវព័ត៌មានតាមបណ្តាគេហទំព័រពាក់ព័ន្ធនឹងវិស័យកសិកម្មចំនួន ៩៣ករណី លើវិស័យព្រៃឈើ២១ករណី ជលផល២៧ករណី សុខភាពសត្វនិងផលិតកម្មសត្វ១៤ករណី កៅស៊ូ១ករណី ក្សេត្រសាស្ត្រ១ករណី និងវិស័យផ្សេងៗ ២៩ករណី

- ចូលរួមប្រជុំទូទៅចំនួន ៨លើក និងចូលរួមពិធីផ្សេងៗ១លើក។

## ៧ ផ្នែករដ្ឋបាល

- បានទទួលលិខិតសរុបចំនួន ៦៧៦ច្បាប់ ក្នុងនោះពីក្រសួង-ស្ថាប័ននានាចំនួន ២៧៣ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ២៨២ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ១២១ច្បាប់ និងបានចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តការងាររដ្ឋបាល

- បានបញ្ជូនឯកសារ និងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ៧៥៥ច្បាប់ ចេញប្រកាស សេចក្តីសម្រេច និងសារាចរចំនួន ៣៦ច្បាប់ និងចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទបានចំនួន ២២ច្បាប់

- បានបូកសរុបរបាយការណ៍របស់ក្រសួងប្រចាំខែកុម្ភៈ

- ថ្នាក់ដឹកនាំនាយកដ្ឋានកិច្ចការរដ្ឋបាលបានសម្របសម្រួលចាត់ចែងក្នុងពិធីផ្សេងៗ និងបានចូលរួមរាល់កិច្ចប្រជុំដើម្បីក្តាប់ឱ្យបានរាល់ការងារពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំនួន ១០លើក មានអ្នកចូលរួម១៦៥នាក់

- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការក្នុងការទទួលគណៈប្រតិភូជាតិ-អន្តរជាតិ៣លើក មានអ្នកចូលរួម២៩នាក់ ការរៀបចំកិច្ចប្រជុំនិងពិធីបុណ្យផ្សេងៗ១លើក មានអ្នកចូលរួម៦០នាក់ ការងារសន្តិសុខសណ្តាប់ធ្នាប់ រួមរបស់ក្រសួងបានល្អ ព្រមទាំងចាត់ចែងលិខិតអញ្ជើញ ផ្សេងៗតាម Telegram ផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈគេហទំព័រ៖ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម)។

## ៨ ផ្នែកបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន ៥ ៩៣៧នាក់ (ស្រី១ ៤៧០នាក់ ស្មើនឹង២៤,៧៥%) រួមមាន៖
  - \+ អង្គភាពថ្នាក់កណ្តាលចំនួន ២ ៩៦៨នាក់ (ស្រី៨៦១នាក់ ស្មើនឹង២៨,៨៣%)
  - \+ អង្គភាពថ្នាក់រាជធានី-ខេត្តចំនួន ២ ៩៥១នាក់ (ស្រី៦០៩នាក់ ស្មើនឹង២០,៦៣%)
- រៀបចំប្រកាសផ្ទេរមន្ត្រីរាជការផ្ទៃក្នុងក្រសួងចំនួន ៩នាក់ និងផ្ទេរចូលក្នុងក្រសួងចំនួន ៣នាក់
- រៀបចំលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកការងារចំនួន ៧នាក់
- រៀបចំសំណើសុំដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍មុនកាលកំណត់ និងបោះពុម្ពសលាកបត្រមន្ត្រីរាជការស៊ីវិលចំនួន ៩នាក់ទៅក្រសួងមុខងារសាធារណៈ
- រៀបចំប្រកាសស្តីពីការដាក់មន្ត្រីរាជការឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សចំនួន ៤នាក់
- រៀបចំប្រកាសស្តីពីសំណើសុំដំឡើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ២០២២ចំនួន ១ ៩៧៥នាក់
- ការងារបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសសរុបចំនួន ២០៣នាក់ (ស្រី៦៥នាក់) ក្នុងនោះ៖
  - \+ ការបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លី និងមធ្យមសរុបចំនួន ១៨១នាក់ (ស្រី៦០នាក់)
  - \+ ការបណ្តុះបណ្តាលក្រៅប្រទេសចំនួន ២២នាក់ (ស្រី៥នាក់)។

## ៩ ផ្នែកផែនការ និងស្ថិតិ

- រៀបចំសំណើសុំព័ត៌មានពាក់ព័ន្ធនឹងបទដ្ឋានអនាម័យ ភូតគាមអនាម័យ និងដំណើរការរដ្ឋបាលសម្រាប់ការនាំចូលផ្លែស្រកានាគមកកម្ពុជា

- រៀបចំសំណើសុំពិនិត្យ និងអនុម័តលើសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០២១-២០៣០

- ចុះធ្វើការណែនាំ និងធ្វើអង្កេតស្ទង់ទិន្នផលស្រូវប្រាំង ឆ្នាំ២០២២ នៅខេត្តក្រចេះ និងខេត្តកំពង់ឆ្នាំងដោយសហការជាមួយមន្ត្រីស្ថិតិថ្នាក់ខេត្ត និងស្រុក

- ចុះប្រមូលព័ត៌មានតម្លៃទីផ្សារកសិផលលក់ដុំក្នុងមួយសប្តាហ៍បីដងគឺថ្ងៃច័ន្ទ ពុធ និងសុក្រ និងតម្លៃលក់រាយម្តងក្នុងសប្តាហ៍រៀងរាល់ថ្ងៃព្រហស្បតិ៍តាមបណ្តាទីផ្សារសំខាន់ៗ ទីតាំងប្រមូលទិញ និងកន្លែងលក់ដុំផលិតផលក្នុងបណ្តារាជធានី-ខេត្តទាំង២៥

- ចុះពិនិត្យ និងតាមដានការស្រង់ព័ត៌មានតម្លៃទីផ្សារកសិកម្មនៅខេត្តបាត់ដំបង ប៉ៃលិន ព្រះវិហារ និងខេត្តឧត្តរ-មានជ័យ

- ចូលរួមប្រជុំជាមួយសហគមន៍ស្ទឹងត្រែងសែនជ័យ ផលិតជី និងចិញ្ចឹមឃ្មុំនៅខេត្តកំពង់ចាម ដើម្បីប្រមូលព័ត៌មានដើម្បីរៀបចំក្រមប្រតិបត្តិបរិស្ថាន ECOP។

## ១០ ផ្នែកគណនេយ្យ ហិរញ្ញវត្ថុ

- អង្គភាពប្រមូលចំណូលទាំង៦បានចុះប្រតិបត្តិការចំណូលក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ(NRMIS) សរុបទឹកប្រាក់ចំនួន ៣ ៥៩៥លានរៀល

- បញ្ចេញអាណត្តិបើកប្រាក់ពីក្រសួងសរុបមានចំនួន ៧ ៦៨៦លានរៀល

- រៀបចំសំណើសុំថវិកាចំនួន ៤៩ ១៧៧,២៣ដុល្លារអាមេរិក និងចំនួន ៣៩ ៤០២,៨៥អឺរ៉ូ សម្រាប់ទូទាត់ជូនក្រុមហ៊ុន Agriconsulting Europe S.A. (AESA) ក្នុងការអនុវត្តកម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាព និងបរិយាប័ន្នផ្នែកវារីវប្បកម្ម (CaPFish Aquaculture) ក្រោមហិរញ្ញប្បទានឥតសំណងរបស់ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD)

- ទទួលថ្លៃសម្បទានដីសេដ្ឋកិច្ចពីក្រុមហ៊ុនចំនួន៦

- រៀបចំលិខិតជូនដំណឹងស្តីពីកាតព្វកិច្ចបង់ថ្លៃសម្បទានដីសេដ្ឋកិច្ចជូនក្រុមហ៊ុនចំនួន២៦

- សហការរៀបចំ និងចូលរួមជាមួយគណៈកម្មការអន្តរក្រសួង (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ចុះពិនិត្យ និងវាយតម្លៃលើការងារអនុវត្តកិច្ចសន្យាស្តីពីការងារហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពនៅតាមសហគមន៍កសិកម្មចំនួន ៨ក្នុងខេត្តគោលដៅចំនួន ៥ (ខេត្តកណ្តាល កំពង់ស្ពឺ កំពង់ឆ្នាំង កំពង់ចាម និងខេត្តត្បូងឃ្មុំ) ក្នុងឆ្នាំ២០២១ ដែលអនុវត្តដោយនាយកដ្ឋានវិស្វកម្មកសិកម្មនៃអគ្គនាយកដ្ឋានកសិកម្ម។

## ១១ ផ្នែកសវនកម្មផ្ទៃក្នុង

- បានរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០១៩ (ឆ្នាំគោល) និងធ្វើការគ្រប់គ្រង បែងចែកសម្ភារការិយាល័យ សង្ហារិម សម្ភារបរិក្ខារបច្ចេកទេស ថែទាំ និងជួសជុល

- បានរៀបចំផែនការយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុងឆ្នាំ២០២១-២០២៣ ផែនការសវនកម្មផ្ទៃក្នុងឆ្នាំ២០២១ ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២១-២០២៣

- រៀចំរបាយការណ៍តាមដាន និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីតាមទម្រង់ M1 ប្រចាំត្រីមាស និងរបាយការណ៍សមិទ្ធកម្មប្រចាំឆមាសទី១ M2 ប្រចាំឆ្នាំ និងរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ។

## ១២ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- ទទួលជួបពិភាក្សាការងារជាមួយស្ថានទូត៥លើក អង្គការអន្តរជាតិ១លើក និងវិស័យឯកជន១លើក

- ចូលរួមកិច្ចប្រជុំចំនួន ១លើក ក្រោមក្របខ័ណ្ឌទ្វេភាគី និងពហុភាគីលើការងារក្រៅប្រទេស

- ចូលរួមសិក្ខាសាលាចំនួន ១លើកក្រោមក្របខ័ណ្ឌទ្វេភាគី និងពហុភាគី និងសិក្ខាសាលា៣លើក ក្រោមក្របខ័ណ្ឌអាស៊ានលើការងារក្រៅប្រទេស

- សម្របសម្រួលរៀបចំរបាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-នូវែលសេឡង់ ដើម្បីត្រៀមរៀបចំកិច្ចពិគ្រោះយោបល់ក្រសួងការបរទេសកម្ពុជា-នូវែលសេឡង់លើកទី២

- សម្របសម្រួលដើម្បីកំណត់យកតារាងនិយ័តកម្មថវិកានៃគម្រោងការកសាងសមត្ថភាពរបស់សមាជិកនៃប្រទេសតាមដងទន្លេមេគង្គ ដើម្បីការពារសត្វផ្សោតទឹកសាប និងជីវចម្រុះ

- រៀបចំកិច្ចអន្តរាគមន៍បញ្ជូនឯកសារទស្សនទានស្តីពីការកែលម្អពូជគោនៅកម្ពុជាទៅកាន់ស្ថានទូតប្រេស៊ីលនៅទីក្រុងបាងកក

- សម្របសម្រួលរៀបចំការចុះហត្ថលេខារវាងអង្គការ FAO ជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចំនួន ១លើក

- សម្របសម្រួលលិខិតករណីសំណើផ្តល់ធាតុចូលលើវិស័យអាទិភាពដែលស្នើឡើងដោយកម្ពុជាសម្រាប់ផែនការការងារនៃកិច្ចសហប្រតិបត្តិការអាស៊ានបូកបីឆ្នាំ២០២៣-២០២៧

- សម្របសម្រួលលិខិតសំណើសុំគោលការណ៍អនុញ្ញាតបែងចែកអង្ករបម្រុងសង្គ្រោះបន្ទាន់អាស៊ានបូកបីដែលផ្តល់ដោយប្រទេសកូរ៉េ ដល់ប្រជាពលរដ្ឋក្រីក្ររងផលប៉ះពាល់ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ ចំនួន៧ ៥០០គ្រួសារ។

## ១៣ ផ្នែកនីតិកម្មកសិកម្ម

### ១៣.១ ការងារអាជីវកម្មជី-ថ្នាំកសិកម្ម

- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាថ្នាំកសិកម្ម និងជីកសិកម្មចំនួន ២០ក្រុមហ៊ុន
- ផ្តល់លិខិតអនុញ្ញាតនាំចូលថ្នាំកសិកម្ម និងជីកសិកម្មចំនួន ២២ក្រុមហ៊ុន
- ផ្តល់វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៦ក្រុមហ៊ុន។

### ១៣.២ ការងារមន្ទីរពិសោធន៍

ធ្វើវិភាគរកសារធាតុបន្ទាប់បន្សំ និងលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំវិភាគចំនួន ៨ក្រុមហ៊ុន សរុបចំនួន ៤០សំណាក។

### ១៣.៣ ការងារអភិវឌ្ឍបទដ្ឋានគតិយុត្ត

- រៀបចំសិក្ខាសាលាស្តីពីគោលការណ៍សម្រាប់ស្លាកសញ្ញាព័ត៌មាន និងគំរូស្លាកសញ្ញាព័ត៌មានថ្នាំកសិកម្មនៅខេត្តបន្ទាយមានជ័យ និងខេត្តពោធិ៍សាត់។

### ១៣.៤ ការងារអនុវត្តច្បាប់

- ចុះត្រួតពិនិត្យក្រុមហ៊ុនប្រកាសប្រតិវេទន៍នាំចូលថ្នាំកសិកម្ម ជីកសិកម្ម និងផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយដល់ក្រុមហ៊ុនពាណិជ្ជកម្មថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៩ក្រុមហ៊ុន

- ចុះធ្វើអធិការកិច្ចត្រួតពិនិត្យបទល្មើសថ្នាំកសិកម្ម និងជីកសិកម្មខេត្តគោលដៅចំនួន ៦ខេត្ត គឺខេត្តកណ្តាល ព្រៃវែង បន្ទាយមានជ័យ បាត់ដំបង ស្ទឹងត្រែង និងខេត្តរតនគិរី ដោយត្រួតពិនិត្យលើ៨ក្រុមហ៊ុន ពុំមានពិន័យអន្តរការណ៍ទេ។

## ១៤ ផ្នែកមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម

- បានថែទាំលើគេហទំព័រ (Web) និង Mobile App របស់ក្រសួង និងអង្គភាពក្រោមឱវាទក្រសួងសរុបចំនួន ១៧ (១៦គេហទំព័រ និង១កម្មវិធី) និងគេហទំព័រមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត

- ចុះតាមដាន និងពង្រឹងការប្រើប្រាស់គេហទំព័ររបស់មន្ទីរ និងប្រមូលធាតុចូលសម្រាប់បង្កើតកម្មវិធីទូរស័ព្ទនៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តចំនួន ៣រួមមានៈ ខេត្តតាកែវ កោះកុង និងខេត្តកែប

- សម្អាត Cache នៅលើ Cloud server នៃគេហទំព័រទាំង៤១ និងតាមដានទិន្នន័យដែលផ្ទុកនៅលើ Cloud server នៃគេហទំព័រទាំង៤១

- តាមដានលើការផ្សព្វផ្សាយសកម្មភាពការងាររបស់អង្គភាពថ្នាក់កណ្តាលលើគេហទំព័រផុសចំនួន ២២ព័ត៌មាន
- ចុះប្រមូលទិន្នន័យដំណាំសក្តានុពលក្នុងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដើម្បីរៀបចំជាផែនទីដំណាំកសិកម្ម
- បណ្ណាល័យកសិកម្មទទួលសៀវភៅ ឯកសារបច្ចេកទេសកសិកម្ម ទស្សនាវដ្តី ដែលទទួលបានពីនាយកដ្ឋាន-កិច្ចការរដ្ឋបាល នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងផ្នែកផ្សេងៗសរុបចំនួន ៧ក្បាល/ច្បាប់
- ការផ្សព្វផ្សាយអំពីបណ្ណាល័យកសិកម្មអេឡិចត្រូនិកដែលមានអ្នកចូលអានចំនួន ៥ ៧៤២ដង/នាក់។

## ១៥ ផ្នែកផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានចុះសិក្សាពីតម្រូវការកសិករលើការផ្សព្វផ្សាយកសិកម្ម តាមរយៈប្រព័ន្ធសេវាព័ត៌មានវិទ្យាកសិកម្មនៅខេត្តកំពង់ឆ្នាំង និងខេត្តព្រះវិហារ

- បានសហការជាមួយទូរទស្សន៍ជាតិកម្ពុជាចុះផលិតខ្សែវីដេអូបទយកការណ៍ស្តីពីបច្ចេកទេសចិញ្ចឹមបង្កង ភ្ញាស់កូនបង្កងលក់ បច្ចេកទេសចិញ្ចឹមមាន់ ភ្ញាស់កូនមាន់លក់ និងការដាំដុះបន្លែសុវត្ថិភាពក្នុងផ្ទះសំណាញ់នៅខេត្តបន្ទាយមានជ័យ

- បានចុះទៅថត Video បទយកការណ៍ចំនួន ១ប្រធានបទ
- បានធ្វើការផលិត Video និងចាក់ផ្សាយឡើងវិញចំនួន ២ប្រធានបទ
- បានផលិត Video នាទីចុះស្រែជាមួយកសិករចំនួន ២ប្រធានបទ
- បានបញ្ជូនអត្ថបទបច្ចេកទេសកសិកម្មចំនួន ៦ដើម្បីចាក់ផ្សាយ។

## ១៦ ផ្នែកកសិ-ឧស្សាហកម្ម

- អនុវត្តកិច្ចសន្យាផលិតកម្មកសិកម្មចំនួន ៤៨កិច្ចសន្យា គិតត្រឹមខែកុម្ភៈ ឆ្នាំ២០២២ រួមមាន៖ ខេត្តពោធិ៍សាត់មានចំនួន ៤កិច្ចសន្យា ត្បូងឃ្មុំមានចំនួន ១កិច្ចសន្យា សៀមរាបមានចំនួន ១១កិច្ចសន្យា កំពង់ចាមមានចំនួន ៤កិច្ចសន្យា ស្វាយរៀងមានចំនួន ១៣កិច្ចសន្យា និងខេត្តបន្ទាយមានជ័យមានចំនួន ១៥កិច្ចសន្យា
- ចុះសម្របសម្រួលបណ្តុះបណ្តាលបុគ្គលិកអំពីប្រព័ន្ធសុវត្ថិភាពចំណីអាហារ (HACCP) និងចុះពិនិត្យការអនុវត្តគ្រប់គ្រងប្រព័ន្ធសុវត្ថិភាពក្នុងការកែច្នៃគ្រាប់ស្វាយចន្ទីនៅខេត្តកំពង់ធំ
- ចុះសិក្សាសក្តានុពលផ្គត់ផ្គង់គ្រឿងសមុទ្រនៅខេត្តព្រះសីហនុ
- ចុះប្រមូលទិន្នន័យ និងធាតុចូលសម្រាប់ការរៀបចំគោលការណ៍ណែនាំពាក់ព័ន្ធនឹងអាហារូបត្ថម្ភនៅខេត្តរតនគិរី
- ចុះសិក្សារៀបចំអភិវឌ្ឍន៍ស្តង់ដារគ្រាប់ស្វាយចន្ទីស្រស់នៅខេត្តកំពង់ចាម និងខេត្តកំពង់ធំ
- ចុះធ្វើសិក្ខាសាលាផ្សព្វផ្សាយស្តីពីការភ្ជាប់ទំនាក់ទំនងកសិករខ្នាតតូចទៅទីផ្សារ តាមរយៈផលិតកម្មកសិកម្មតាមកិច្ចសន្យានៅខេត្តកំពង់ឆ្នាំង
- ចុះធ្វើសិក្ខាសាលាផ្សព្វផ្សាយស្តីពីការជំរុញការនាំចេញផលិតកម្មកសិកម្មតាមកិច្ចសន្យាតាមរយៈការពង្រឹងការអនុវត្តផលិតកម្មតាមកិច្ចសន្យាជាមួយក្រុមហ៊ុន រោងចក្រ សហគ្រាសនៅខេត្តកំពង់ធំ
- ចុះបណ្តុះបណ្តាលស្តីពីបច្ចេកទេសកែច្នៃបន្លែ ផ្លែឈើ និងគ្រាប់ធញ្ញជាតិនៅខេត្តសៀមរាប
- ចុះបណ្តុះបណ្តាលស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យានៅខេត្តកំពត
- ចុះបណ្តុះបណ្តាលស្តីពីការលើកកម្ពស់ស្តង់ដារគុណភាព និងសុវត្ថិភាពនៃផលិតផលកសិកម្មនៅខេត្តរតនគិរី
- ចុះបណ្តុះបណ្តាលស្តីពីបច្ចេកទេសក្រោយប្រមូលផលនៃផលិតកម្មកសិកម្មនៅខេត្តបាត់ដំបង
- ចុះធ្វើសិក្ខាសាលាផ្សព្វផ្សាយស្តីពីលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ពាក់ព័ន្ធនឹងផលិតកម្មកសិកម្មតាមកិច្ចសន្យានៅខេត្តព្រៃវែង
- ចុះធ្វើសិក្ខាសាលាផ្សព្វផ្សាយស្តីពីការស្រាវជ្រាវ និងពង្រឹងភាគីដែលបាននិងកំពុងអនុវត្តកិច្ចសន្យាផលិតកម្មកសិកម្មនៅខេត្តកំពង់ស្ពឺ
- បាននិងកំពុងពិភាក្សាពិគ្រោះយោបល់ និងរៀបចំពិធីការជាមួយអ្នកជំនាញការបច្ចេកទេស MRLs ដើម្បីអនុវត្តការសិក្សាស្រាវជ្រាវកាត់បន្ថយកម្រិតកាកសំណល់ថ្នាំកសិកម្មក្នុងការដាំដុះប្រភេទដំឡូងវង់ដោយប្រើប្រាស់ថ្នាំពុលកសិកម្មក្លរភីរីហ្វូស និងសាយភីមេហ្សិន។

## ១៧ ការស្រាវជ្រាវ ការអប់រំ និងការបណ្តុះបណ្តាលកសិកម្ម

### ១៧.១ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- ចូលរួមសិក្ខាសាលាស្តីពីការបង្ហាញនូវលទ្ធផលបច្ចេកវិទ្យាធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុសម្រាប់ដំណាំសិប្បកម្ម និងការត្រួតពិនិត្យលើផែនការសកម្មភាពអាទិភាពនៃការប្រែប្រួលអាកាសធាតុឆ្នាំ២០១៦-២០២២
- ចូលរួមពិព័រណ៍ទីផ្សារកសិកម្មក្រោមប្រធានបទនវានុវត្តន៍សម្រាប់ប្រព័ន្ធកសិកម្មប្រកបដោយនិរន្តរភាព និងកសិកម្មធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុ
- ចូលរួមសិក្ខាសិលាស្តីពីការរៀបចំកម្មវិធីវិនិយោគសាធារណៈ (ក.វ.ស) ៣ឆ្នាំរំកិល ២០២៣-២០២៥
- ចុះពិនិត្យមើលការងារពិសោធន៍ និងរៀបចំទីតាំងសម្រាប់ការងារពិសោធន៍ស្រាវជ្រាវនៅខេត្តព្រះវិហារ។

### ១៧.២ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតកំពុងសិក្សាក្នុងឆ្នាំសិក្សា២០២២សរុបចំនួន ៣ ២៥៦នាក់ ចែកចេញជា១០ មហាវិទ្យាល័យ គឺ៖ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិស្វកម្មកសិកម្ម វិទ្យាសាស្ត្រជលផល កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ រៀបចំដែនដីនិងរដ្ឋបាលដីធ្លី និងមហាវិទ្យាល័យវិទ្យា-សាស្ត្រកៅស៊ូ និងសាលាក្រោយឧត្តម
- រៀបចំសិក្ខាសាលាស្តីពីការកែលម្អមាតិកា និងខ្លឹមសារមេរៀន ព្រមទាំងវិធីសាស្ត្របង្រៀនសម្រាប់មហាវិទ្យាល័យនៅខេត្តកំពតដែលគាំទ្រដោយគម្រោង HEIP
- ជួបពិភាក្សាជាមួយ GIZ ដែលបាននិងកំពុងអនុវត្តគម្រោងជំងឺផ្តេក្អួតនៅកម្ពុជាលើផែនការសកម្មភាពចាក់វ៉ាក់សាំងជំងឺផ្តេក្អួតទ្រង់ទ្រាយធំនៅកម្ពុជា

- ជួបប្រជុំពិភាក្សាការងារជាមួយក្រុមហ៊ុន iL-Brille និងដំណើរទស្សនកិច្ចនៅមន្ទីរពិសោធន៍ចម្រាញ់និងវិភាគគុណភាពប្រេងអ៊ីនពីសម្បកជង្គូវនាង

- រៀបចំកម្មវិធីប្រកួតប្រជែង Cambodia Agri-Food Innovation Challenge ក្រោមការឧបត្ថម្ភដោយគម្រោង Food-STEM។

### ១៧.៣ វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០២២ សរុបចំនួន ១ ៣៦២នាក់ (ស្រី៣៧៤នាក់) លើជំនាញ៖ កសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិស្វកម្មកសិកម្ម ព្រៃឈើ ជលផល សាកវប្បកម្ម សុរិយោដីនិងការគ្រប់គ្រងដី ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចកសិកម្ម មីក្រូហិរញ្ញវត្ថុ កែច្នៃអាហារ កុំព្យូទ័រ សេដ្ឋកិច្ចនយោបាយនិងស្បៀង និងភាសាអង់គ្លេស

- បាននិងកំពុងជំរុញការងារស្រាវជ្រាវ និងសហប្រតិបត្តិការជាមួយដៃគូ ដើម្បីជាប្រយោជន៍សម្រាប់ការសិក្សាស្រាវជ្រាវរបស់និស្សិត និងមន្ត្រីដោយការសិក្សាស្រាវជ្រាវផ្តោតលើ៖ ត្រី បង្កង បង្គា មាន់ ទា ពពែ ក្របី គោទឹកដោះ បន្លែ ផ្កា ឫស្សី ស្រូវ ចេក ស្វាយចន្ទី កាកាវ វ៉ានីឡា ស្ពៃ អាហារ ថ្នាំសត្វល្អិត និងដី

- សហប្រតិបត្តិការសំខាន់ៗរួមមានការបណ្តុះជាលិការុក្ខជាតិ អាក្វាពោនិក (ប្រព័ន្ធវារីវប្បកម្ម) ការកែច្នៃស្វាយចន្ទី ការផលិតម្សៅឫស្សី ការចិញ្ចឹមគោទឹកដោះ ការពិសោធដំណាំជប៉ុន និងការសរសេរសៀវភៅសម្រាប់ការបណ្តុះបណ្តាលរបស់វិទ្យាស្ថាន។

### ១៧.៤ វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០២២ សរុបចំនួន ៦១០នាក់ (ស្រី២៧៤នាក់) លើជំនាញវិទ្យាសាស្ត្រកសិកម្ម កសិក្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- ពិសោធន៍លើជីសរីរាង្គពីការលូតលាស់ដំណាំបន្លែស្ពៃក្រញាញ់

- ពិសោធន៍តាមដានការបំផ្លាញរបស់កត្តាចង្រៃលើដំណាំខាត់ណាផ្កា

- បានធ្វើការបង្កាត់ពូជកង្កែប និងត្រីទីឡាព្យ៉ាក្រហមនៅស្ថានីយពិសោធន៍ជលផលនៃវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- បានធ្វើការសាកល្បងចម្រាញ់ប្រេងស្វាយចន្ទីសម្រាប់ផលិតជាគ្រឿងក្រអូប

- បានចូលរួមបណ្តុះបណ្តាលកសិករជាមួយដៃគូរបស់ក្រុមហ៊ុន និងធ្វើការស្រាវជ្រាវរួមគ្នាអំពីការកែច្នៃកសិផលលើដំណាំស្វាយចន្ទី ល្ហុង ល្ពៅ ក្រូចថ្លុង ស្លឹកគ្រៃ និងម្រេច។

### ១៧.៥ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- ត្រួតពិនិត្យទូទៅការការពារ និងថែទាំចម្ការពិសោធន៍ក្លូនកូនកៅស៊ូស៊ីដលីង និងច្បារបង្កាត់ពូជ

- ស្រង់ទិន្នន័យ បញ្ចូល និងវិភាគទិន្នន័យចម្ការពិសោធន៍ក្លូន (ទិន្នផលជ័រ) សរុបចំនួន ១២ចម្ការពិសោធន៍

- ត្រួតពិនិត្យចម្ការបង្ហាញនៅខេត្តមណ្ឌលគិរីស្តីពីការអនុវត្តកសិកម្មល្អលើការយកផលទឹកជ័រ ដោយមានការសហការជាមួយអគ្គនាយកដ្ឋានកៅស៊ូ និងអង្គការ WWF-កម្ពុជា

- ត្រួតពិនិត្យការចៀរជ័រ ការសាប្រមូលផលទឹកជ័រ ស្រង់ទិន្នន័យ បញ្ចូល និងវិភាគទិន្នន័យជ័រកៅស៊ូតាមពិធីសាពិសោធន៍គ្រប់ចម្ការពិសោធន៍

- រៀបចំលាយសូលុយស្យុងវត្ថុធាតុគីមី និងវិភាគរកស្តង់ដារសរីរទឹកជ័រ (Latex diagnosis-LD) លើប៉ារ៉ាម៉ែត្រ Inorganic Phosphorus (Pi), Sucrose) Suc) និង Thiol (R-SH)

- ថែទាំកូនកៅស៊ូនៅថ្នាលបណ្តុះកូនឆ្នាំ២០២១-២០២២

- អនុវត្តការបំបៅកូនកៅស៊ូនៅថ្នាលបណ្តុះកូនកៅស៊ូឆ្នាំ២០២១-២០២២

- ត្រួតពិនិត្យការកែច្នៃកៅស៊ូសន្លឹក និងជួសជុលថែទាំឧបករណ៍កែច្នៃនៅក្នុងរោងចក្រ

- ពិភាក្សាការងារជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្តីពីការវាយតម្លៃ និងទទួលស្គាល់ស្តង់ដារ ISO/IEC 17025: 2017

- ធ្វើតេស្តកៅស៊ូសន្លឹក (RSS) ចំនួន ៨សំណាក ដើម្បីពិនិត្យគុណភាពនៃការកែច្នៃតាមស្តង់ដារ CSR។

III-សេចក្តីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារបង្កបង្កើនផលស្រូវរដូវប្រាំងសម្រេចបានចំនួន ៦៣៧ ១៦៥ហ.ត ស្មើនឹង១៣៧,៨៣% នៃផែនការចំនួន ៤៦២ ២៨០ហ.ត ការប្រមូលផលស្រូវប្រាំងសម្រេចបានចំនួន ២៥៦ ៧៣១ហ.ត ដោយទទួលបរិមាណផលសរុបចំនួន ១ ១៤៨ ០៧៥តោន និងទទួលទិន្នផលគិតជាមធ្យម ៤,៤៧២តោន/ហ.ត។ ក្រសួងបានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់គិតគូរទៅលើការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងការស្តារការប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ ការរាតត្បាតដោយសមាសភាពចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ការជំរុញឱ្យចុះត្រួតពិនិត្យ និងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វឈឺក្នុងតំបន់ផ្ទុះជំងឺ បទល្មើសព្រៃឈើ និងបទល្មើសជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រងការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងបានបន្តជំរុញឱ្យគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ផ្សេងៗតាមអនុវិស័យសំខាន់ៗ ជាអាទិ៍ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រឱ្យសម្រេចបាននូវលទ្ធផលល្អប្រសើរតាមផ្នែកនីមួយៗស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម។

IV- ទិសដៅអនុវត្តបន្ត

១ ផ្នែកដាំដុះ

- បន្តវិធានការជំរុញការងារបង្កបង្កើនផលកសិកម្ម
- បន្តធ្វើការជំរុញផលិតកម្មស្បៀងសម្រាប់ឆ្លើយតបទៅនឹងហានិភ័យនៃការឆ្លងរាលដាលជំងឺកូវីដ-១៩
- បន្តជំរុញការនាំចេញផលិតផលកសិកម្មទៅកាន់ទីផ្សារអន្តរជាតិពិសេសប្រទេសចិន
- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវ និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណ និងគុណភាពតាមផែនការកំណត់ ជាពិសេសនៅតំបន់ភូមិសាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ និងការរក្សាទឹកទុកទៅតាមស្ថានភាពជាក់ស្តែង
- បន្តជំរុញ និងបណ្តុះបណ្តាលមន្ត្រីបច្ចេកទេស និងកសិករអំពីបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម និងបន្តការសិក្សាស្រាវជ្រាវបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម ការងារផលិតពូជ និងបន្សុទ្ធពូជនៅកសិដ្ឋាន និងស្ថានីយ
- ត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់នឹងជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្ម
- បន្តអង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡត៍ពិសោធន៍កូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ។

២ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗ ចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង
- បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់

ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី-ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- បន្តពង្រឹង និងផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមសត្វដល់កសិករ

- ត្រៀមលក្ខណៈចុះអនុវត្តវិធានការបសុព្យាបាលកន្លែងផ្ទុះជំងឺ និងកន្លែងដែលរាលដាលជំងឺផ្តាសាយបក្សី (H5N1) ជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF) ជំងឺដុំពកស្បែកគោ ក្របី (LSD) និងជំងឺឆ្លងសត្វផ្សេងៗ

- បន្តការតាមដានស្ថានភាពជំងឺស៊ូណូសជាប្រចាំនៅតាមបណ្តារាជធានី-ខេត្ត

- ជំរុញការអនុវត្តកម្មវិធីផ្សព្វផ្សាយលើកកម្ពស់ការអប់រំយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការប្រើប្រាស់ចំណីសត្វ និងបសុឱសថដល់អាជីវករ និងអ្នកប្រើប្រាស់

- បន្តចុះវាយតម្លៃកសិដ្ឋានចិញ្ចឹមសត្វស្របតាមបច្ចេកទេស និងគោលការណ៍អនុវត្តការចិញ្ចឹមសត្វល្អ តាមខេត្តគោលដៅ

- បន្តរៀបចំឯកសារស្តីពីអត្ថប្រយោជន៍នៃការគ្រប់គ្រងកាកសំណល់សត្វ។

## ៣ ផ្នែកព្រៃឈើ

- ខិតខំបន្តត្រួតពិនិត្យ តាមដាន និងពង្រឹងការគ្រប់គ្រងសកម្មភាពឧស្សាហកម្មឈើ រោងចក្រ សិប្បកម្មកែច្នៃ និងអាជីវកម្មឈើឲ្យបានហ្មត់ចត់ ព្រមទាំងចាត់វិធានការទប់ស្កាត់ និងលុបបំបាត់ការនាំចេញឈើ និងផលិតផលកែច្នៃឈើគ្រប់ប្រភេទដែលគ្មានការអនុញ្ញាតដើម្បីលុបបំបាត់សកម្មភាពដឹកជញ្ជូនឈើខុសច្បាប់ឲ្យមានប្រសិទ្ធភាពខ្ពស់

- បន្តពង្រឹង និងពង្រីកសហគមន៍ព្រៃឈើចូលរួមគ្រប់គ្រងថែរក្សាធនធានព្រៃឈើ តាមដានត្រួតពិនិត្យ ការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍ឱ្យបានល្អ ព្រមទាំងបណ្តុះផ្នត់គំនិតបង្កើតមុខរបរថ្មីៗបន្ថែមទៀត ដើម្បីបង្កើនចំណូលតាមរយៈប្រព័ន្ធកសិ-រុក្ខកម្ម ការចិញ្ចឹមសត្វ សំដៅកាត់បន្ថយការពឹងអាស្រ័យលើផល និងអនុផលព្រៃឈើ ជាពិសេសខិតខំជំរុញការផ្សព្វផ្សាយ អប់រំ បណ្តុះបណ្តាល បំពាក់បំប៉នដល់សហគមន៍មូលដ្ឋានយល់ដឹងពីផលប្រយោជន៍ព្រៃឈើ

- បន្តផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ បទប្បញ្ញត្តិ បទបញ្ជា លិខិតបទដ្ឋានគតិយុត្ត ជាពិសេសសេចក្តីជូនដំណឹងលេខ១៣៤៨ សជណ.កត ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រីឱ្យបានជ្រួតជ្រាបដល់មូលដ្ឋាន ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង រាជធានី-ខេត្តទូទាំងប្រទេស ព្រមទាំងមានចំណាត់ការផ្លូវច្បាប់យ៉ាងម៉ឺងម៉ាត់ និងមានប្រសិទ្ធភាពខ្ពស់ពាក់ព័ន្ធនឹងការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើដើម្បីវាតយកដីធ្វើកម្មសិទ្ធិ

- បន្តជំរុញការដាំដុះស្តារព្រៃឈើឡើងវិញដោយសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងបង្កើនការបណ្តុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើសម្រាប់ចែកចាយជូនប្រជាពលរដ្ឋ។

## ៤ ផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្តីសម្រេចលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប

- ជំរុញសង្កាត់ ផ្នែក ខណ្ឌរដ្ឋបាលជលផល និងអធិការដ្ឋានរដ្ឋបាលជលផល បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីជលផលឱ្យបានតឹងរ៉ឹងបំផុត

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវ និងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"។

## ៥ ផ្នែកពាក់ព័ន្ធផ្សេងៗ

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់ជី-ថ្នាំកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់ជី-ថ្នាំកសិកម្ម ដើម្បីសុខភាពសាធារណៈ

- បន្តពង្រឹងការងារបញ្ជីកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលសម្រាប់បង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្ដាអង្គភាពក្រោមឱវាទ និងតាមសកម្មភាពជាក់ស្ដែង រួមទាំងការរៀបចំវគ្គបណ្ដុះបណ្ដាលតាមផែនការប្រចាំឆ្នាំដែលបានគ្រោងទុក

- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យនីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា អភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាឱ្យមានផលិតភាពខ្ពស់ដោយគិតគូរទៅលើការប្រែប្រួលអាកាសធាតុ និងស្តង់ដារ។

ថ្ងៃ ព្រហស្បតិ៍ ១១កើត ខែ ជេស្ឋ ឆ្នាំ ខាល ចត្វាស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០២២

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**